ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សរណន

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨

ទិវាវប្បធម៌ជាតិ៣មីនា ជាទិវាដ៏សំខាន់មួយរបស់ប្រទេសជាតិ ដែលជានិច្ចកាលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់រៀបចំប្រារព្ធពិធីជារៀងរាល់ឆ្នាំ ដើម្បីរំលឹកដល់គុណូបការៈ និងស្នាដៃដ៏វិសេសវិសាលរបស់បុព្វបុរសនៃយើង ដែលបានបន្សល់ទុកនូវកេរមរតកវប្បធម៌ដ៏សម្បូរបែបនិងមានតម្លៃមិនអាចកាត់ថ្លៃបានដល់កូនចៅជំនាន់ក្រោយ។ ការប្រារព្ធទិវាវប្បធម៌ជាតិ ជាការជំរុញការផ្សព្វផ្សាយ ការផ្ទេរចំណេះដឹង ចំណេះធ្វើ ជំនាញបច្ចេកទេស និងទេពកោសល្យវប្បធម៌ ក៏ដូចជាការក្រើនរំឭក បំផុសស្មារតីស្រឡាញ់វប្បធម៌ជាតិ និងមនសិការស្នេហាជាតិ ដល់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសយុវជនដែលជាទំពាំងស្នងឬស្សី ដែលមានកាតព្វកិច្ចថែរក្សាការពារឱ្យស្ថិតស្ថេរគង់វង្សនូវសម្បត្តិវប្បធម៌ជាតិ និងវប្បធម៌ចម្រុះនៃសហគមន៍ជនជាតិនៅព្រះរាជាណាចក្រកម្ពុជា សំដៅរក្សាបាននូវឯកភាពជាតិ សាមគ្គីភាព សន្តិភាព និងការអភិវឌ្ឍ។

អនុលោមតាមស្មារតីខាងលើ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចឱ្យប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨ ដោយរក្សានូវប្រធានបទដដែលដូចឆ្នាំ២០១៧ គឺ៖ "**យុវជនដើម្បីវប្បធម៌ជាតិ**" និងកំណត់យកថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ ដើម្បីប្រារព្ធពិធីបើកជាផ្លូវការ។ ក្នុងន័យជំរុញឱ្យយុវជន ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ ចូលរួមអនុវត្តកាន់តែសកម្មថែមទៀត ដើម្បីធ្វើឱ្យបានសម្រេចនូវគោលបំណងជាសារវន្តដូចខាងក្រោម៖

- បង្កើនការស្រឡាញ់ មានស្មារតីចូលរួមក្នុងការផ្ទេរ និងទទួលយកនូវចំណេះដឹង ជំនាញបច្ចេកទេសសិល្បៈវប្បធម៌ សំដៅលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ក៏ដូចជាវប្បធម៌ចម្រុះនៅកម្ពុជាឱ្យបានស្ថិតស្ថេរគង់វង្ស ដែលជាមូលដ្ឋាននៃសាមគ្គីភាព ឯកភាពជាតិ សុខដុមរមនា និងភាពសុខសាន្តរបស់សង្គមជាតិ។
- លើកកម្ពស់ការយល់ដឹងកាន់តែច្បាស់អំពីតម្លៃពិតនៃវប្បធម៌ជាតិ ដែលជាប្រភពធនធានមិនចេះរីងស្ងួតប្រកបដោយសក្តានុពលខ្ពស់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការបង្កើតសេវាកម្ម និងផលិតផលវប្បធម៌ សម្រាប់គោលដៅពាណិជ្ជកម្ម និងទេសចរណ៍។
- បង្កើនការចូលរួមក្នុងការសិក្សា ស្រាវជ្រាវ ឈ្វេងយល់ ដើម្បីចងក្រងរក្សាទុកឱ្យបានគង់វង្សល្អនូវរាល់ឯកសារបេតិកភណ្ឌវប្បធម៌គ្រប់ប្រភេទដែលមានក្នុងមូលដ្ឋានរបស់ខ្លួនព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។
- លើកស្ទួយការប្រើប្រាស់សក្តានុពលវប្បធម៌ ក្នុងន័យដើម្បីបង្កើនការងារ និងកាលានុវត្តភាពដល់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសយុវជន ឱ្យខិតខំបង្កបង្កើតស្នាដៃវប្បធម៌ថ្មីៗប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- ជំរុញឱ្យមានការចូលរួមដោយការទទួលខុសត្រូវរបស់យុវជន ក្នុងកិច្ចអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ព្រមទាំងលើកស្ទួយនូវវប្បធម៌ចម្រុះឱ្យទទួលបាននូវវឌ្ឍនភាពប្រកបដោយនិរន្តរភាព និងសន្តិភាពដោយមិនប្រកាន់នូវ

និន្នាការនយោបាយ ជំនឿសាសនា និងពណ៌សម្បុរ។

ដើម្បីឱ្យការប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨ ក្រោមប្រធានបទ "**យុវជនដើម្បីវប្បធម៌ជាតិ**" ប្រព្រឹត្តទៅដោយជោគជ័យ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ៖

១. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវសហការជាមួយ ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី ដែលជាសមាជិកគណៈកម្មការអន្តរក្រសួងរៀបចំទិវាវប្បធម៌ជាតិ ៣មីនា និងបណ្តាអង្គការជាតិ អង្គការអន្តរជាតិ សហគ្រាសរដ្ឋ និងឯកជន រៀបចំទិវាវប្បធម៌ជាតិ ៣មីនា ឆ្នាំ២០១៨ នេះ ឱ្យបានអធិកអធម។ នៅតាមរោងចក្រសហគ្រាស និងគ្រប់លំនៅដ្ឋានប្រជាពលរដ្ឋត្រូវលើកទង់ជាតិ ទង់ផ្កាលា បដាពាក្យស្លោក បិទគំនូរផ្សាយ(Poster) តាមទីកន្លែងផងផ្លូវសាធារណៈ ទីលានសាធារណៈ អង្គភាព និងលំនៅឋានរបស់ខ្លួនឱ្យបានគ្រប់ៗគ្នាចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨។

២. ក្រសួងព័ត៌មាន ត្រូវរៀបចំកម្មវិធីផ្សព្វផ្សាយ ឱ្យបានទូលំទូលាយតាមបណ្តាញសារព័ត៌មានជាតិ និងឯកជនរួមមាន វិទ្យុ ទូរទស្សន៍ កាសែត និងទស្សនាវដ្តី នូវខ្លឹមសារនៃទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៨ ព្រមទាំងឯកសារពាក់ព័ន្ធ ដើម្បីបំផុស ឱ្យសាធារណជនយល់ដឹង និងចូលរួមកាន់តែសកម្មថែមទៀត ក្នុងការថែរក្សាការពារសម្បត្តិវប្បធម៌ លើកស្ទួយវប្បធម៌ជាតិ សីលធម៌សង្គម និងចេះរួមរស់ជាមួយគ្នាដោយភាពសាមគ្គីជាធ្លុងមួយ មិនប្រកាន់និន្នាការនយោបាយ ឱ្យស្របតាមប្រធានបទ "**យុវជន ដើម្បីវប្បធម៌ជាតិ**"។

៣. ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវសហការរៀបចំកម្មវិធីប្រកួតប្រជែង ក្នុងមជ្ឈដ្ឋាននិស្សិត សិស្ស តាមរយៈការបង្កើតសកម្មភាព ប្រឡងប្រជែងក្នុងការជជែកវែកញែកអំពីចំណេះដឹងវប្បធម៌ និងការចូលរួមប្រឡងក្នុងមហោស្រពសិល្បៈវប្បធម៌ដោយផ្តោតទៅលើប្រធានបទ "**យុវជនដើម្បីវប្បធម៌ជាតិ**"។

៤. ក្រសួងទេសចរណ៍ ត្រូវធ្វើការផ្សព្វផ្សាយនូវខ្លឹមសារទេសចរណ៍វប្បធម៌ ឱ្យបានទូលំទូលាយ តាមគ្រប់រូបភាពជាពិសេសក្នុងចំណោមភ្ញៀវទេសចរជាតិ និងអន្តរជាតិ តាមរយៈទីភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍គ្រប់ប្រភេទ សំដៅបង្កើនការទាក់ទាញ។

៥. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវណែនាំដល់គ្រប់ឯកអគ្គរាជទូត អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេសឱ្យរៀបចំទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨។

៦. ក្រសួងធម្មការ និងសាសនា ត្រូវបំផុសចលនាព្រះសង្ឃ និងគ្រប់សាសនិក ឱ្យរៀបចំកម្មវិធីវប្បធម៌ ក៏ដូចជាការផ្សព្វផ្សាយខ្លឹមសារទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨ នៅតាមទីអារាម ព្រះវិហារ មណ្ឌលវិបស្សនា និងទីសក្ការៈផ្សេងៗ។

៧. អាជ្ញាធរអប្សរា អាជ្ញាធរជាតិព្រះវិហារ អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវរំលេចឡើងនូវខ្លឹមសារការងារជោគជ័យរបស់ស្ថាប័ននីមួយៗក្នុងការថែរក្សា ការពារ អភិរក្ស និងលើកតម្កើងតម្លៃបេតិកភណ្ឌវប្បធម៌ជាតិដ៏វិសេសវិសាលឱ្យបានគង់វង្ស ប្រកបដោយទិដ្ឋភាពស់រវើក និងមានតម្លៃលេចធ្លោជាសកល ដើម្បីអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨ ឱ្យកាន់តែអធិកអធម។

៨. សាលារាជធានី ខេត្ត ត្រូវចូលរួមជួយឧបត្ថម្ភគាំទ្រ និងបង្កលក្ខណៈឱ្យមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំប្រារព្ធពិធីមិទ្ទិញអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឆ្នាំ២០១៨ នៅក្នុងដែនដីរបស់ខ្លួន ដោយមានកម្មវិធីសម្តែងសិល្បៈទស្សនីយភាពជូនសាធារណជនទស្សនាកំសាន្ត និងផ្តោតជាសំខាន់ទៅលើការផ្សព្វផ្សាយអប់រំប្រជាជន មហាជន ជាពិសេសក្នុងស្រទាប់យុវជន ឱ្យកាន់តែមានស្មារតីមុតមាំថែមទៀត ក្នុងការចូលរួមថែរក្សា ការពារ និងលើកកម្ពស់តម្លៃវប្បធម៌ជាតិ ដែលជាការបង្ហាញនូវសុច្ឆន្ទៈប្រកបដោយមនសិការស្នេហាជាតិ ជាគ្រឹះនៃសាមគ្គីភាព ឯកភាពជាតិ គ្មានការរើសអើង គ្មានការប្រកាន់និន្នាការ ពូជសាសន៍ ឬ

ពណ៌សម្បូរឡើយ។ ក្នុងស្មារតីចូលរួមថែរក្សាការពារ លើកស្ទួយវប្បធម៌ជាតិ និងញ៉ាំងឱ្យពិធីកាន់តែអធិកអធមផង គ្រប់សមាជិក សមាជិកាដែលចូលរួមក្នុងព្រឹត្តិការណ៍ទិវាវប្បធម៌ជាតិ ៣មីនា ត្រូវស្លៀកពាក់ឱ្យបានសមរម្យតាមបែបបទប្រពៃណីជាតិ ។

៩. ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំបែងចែកកងកម្លាំង សហការការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅតាមទីកន្លែងប្រារព្ធពិធីទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ឱ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

១០. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី បណ្តាអង្គការ សមាគម ដៃគូអភិវឌ្ឍ និងវិស័យឯកជនដែលកំពុងប្រតិបត្តិការលើវិស័យនានាទាក់ទងនឹងការងារវប្បធម៌ ដើម្បីចាត់តាំងរៀបចំកម្មវិធីសំណេះសំណាលរវាងថ្នាក់ដឹកនាំរាជរដ្ឋាភិបាលជាមួយសិល្បករ សិល្បការិនីទូទាំងប្រទេស នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ ក្នុងឱកាសនៃការប្រារព្ធពិធីអបអរទិវាវប្បធម៌ជាតិ លើកទី២០ ឆ្នាំ២០១៨នេះ។

១១. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើជាលេខាធិការដ្ឋានក្នុងការរៀបចំឯកសារឃោសនាផ្សព្វផ្សាយ បម្រើឱ្យខ្លឹមសារទិវាវប្បធម៌ជាតិ និងត្រូវដឹកនាំគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ក្នុងការរៀបចំទិវាវប្បធម៌ជាតិឱ្យបានអធិកអធម នៅក្នុងអំឡុងដើមខែមីនា ឆ្នាំ២០១៨ និងត្រូវឱ្យមានការចូលរួមពីគ្រប់សហគមន៍ជនជាតិ ដែលរស់នៅលើទឹកដីភូមិសាស្ត្ររបស់ខ្លួន។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ពោងចក្រសហគ្រាសរដ្ឋ និងឯកជន នៅទូទាំងប្រទេស ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

*ថ្ងៃ អង្គារ ៧ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១*

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១៨

[illegible]

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី និងខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ